Children's Community Education - ការអប់រំសហគមន៍របស់កុមារ

# Booster Seats - កៅអីបន្ទុប



## តើអ្វីជាកៅអីបន្ទុប?

កៅអីបន្ទុបគឺជាកៅអីទារកដែលគ្មានរបាំងទាំងសង្ខាង ។ កៅអីនេះជួយលើកក្មេងឡើងឲ្យខ្ពស់ ដើម្បីឲ្យខ្សែក្រវ៉ាត់លើភ្លៅ និងស្មារបស់ក្មេងត្រូវល្មម ។ ក្មេងប្រើកៅអីបន្ទុបកាលណាខ្លួនគេធំជាងកៅអីធម្មតា តែមិនល្មមនឹងខ្សែក្រវ៉ាត់កៅអីឡានធម្មតា ។ ខ្សែក្រវ៉ាត់ដែលមិនត្រូវល្មមនឹងខ្លួនគឺមិនអាចការពារខ្លួនគេបានឡើយ កាលណាមានគ្រោះថ្នាក់បុកគ្នា ។ កៅអីបន្ទុបអាចដោះស្រាយបញ្ហានេះបាន ។

នៅក្នុងរដ្ឋវ៉ាស៊ីនតោន ជាច្បាប់របស់រដ្ឋដែលគ្រប់ក្មេងៗទាំងអស់ត្រូវជិះក្នុងកៅអីបន្ទុបរហូតដល់អាយុ 8 ឆ្នាំ ឬរហូតគេមានកំពស់ 4 ហ្វីត 9 អ៊ីង្ឈ (57 អ៊ីង្ឈ) ។ ក្មេងដែលមានអាយុក្រោម 13 ឆ្នាំ គួរតែជិះនៅកៅអីឡានខាងក្រោយគ្រប់ពេលទាំងអស់ បើសិនជាអាចធ្វើបាន ។

កុំប្រើកៅអីបន្ទុបជាមួយតែខ្សែក្រវ៉ាត់លើភ្លៅតែមួយមុខ ។ កៅអីបន្ទុបត្រូវតែប្រើជាមួយខ្សែក្រវ៉ាត់លើភ្លៅនិងស្មា ។

## ឡានរបស់ខ្ញុំមានតែខ្សែក្រវ៉ាត់លើភ្លៅ ។ តើខ្ញុំត្រូវធ្វើយ៉ាងណា?

ចូរសាកល្បងធ្វើជំរើសទាំងឡាយខាងក្រោម៖

- ប្រើកៅអីបន្ទុបនៅកៅអីខាងមុខជាមួយខ្សែក្រវ៉ាតលើភ្លៅ និងស្មា ។ រុញកៅអីមុខនោះថយក្រោយឲ្យឆ្ងាយបើអាចធ្វើបាន ដើម្បីរក្សាកូនអ្នកឲ្យឆ្ងាយពីប៉ាណ្ណូបរិធានស្ទង់ ។
- កុំដាក់កូនរបស់អ្នកឲ្យអង្គុយនៅកៅអីខាងមុខឲ្យសោះ បើសិនជាឡានរបស់អ្នកមានស្បោងខ្យល់ ។
- បើសិនជាអ្នកត្រូវតែប្រើខ្សែក្រវ៉ាត់លើភ្លៅ អ្នកត្រូវតែពាក់វាឲ្យទាប ហើយដាក់ខ្សែងលើភ្លៅទាំងពីរ ។
- ទូរស័ព្ទមកអង្គការ Safety Restraint Coalition តាមលេខ (425) 828-8975 or (800) 282-5587 (800-BUCK-L-UP) សំរាប់ជំរើសផ្សេងទៀត ។

តើមានកៅអីបន្ទុបប៉ុន្មានប្រភេទ?
កៅអីបន្ទុបមានពីរប្រភេទ ។

- កៅអីបន្ទុបដែលគ្មានបង្អែកអាចប្រើនៅក្នុងឡានដែលមានប្រដាប់កល់ក្បាលនៅកៅអីជិះខាងក្រោយ ឬបង្អែកពីក្រោយដែលមានកំពស់លើត្រចៀកកូនអ្នកកាលណាគេអង្គុយលើកៅ អីបន្ទុប
- កៅអីបន្ទុបមានបង្អែកអាចប្រើនៅក្នុងឡានដែលគ្មានប្រដាប់កល់ក្បាល ។



កៅអីបន្ទុបគ្មានបង្អែក



កៅអីបន្ទុបមានបង្អែក

### ដើម្បីស្វែងយល់ច្រើនថែមទៀត

- វិបសៃយ៏អង្គការ Booster Seat Coalition: www.boosterseat.org
- អង្គការ Safety Restraint Coalition
  - (425) 828-8975
  - (800) 282-5587 (800-BUCK-L-UP)
  - www.800bucklup.org

*មន្ទីរពេទ្យកុមារ នឹងធ្វើឲ្យព័ត៌មាននេះមានជូនជាទម្រង់ផ្សេងទៀតតាមការស្នើសុំ ។ សូមទូរស័ព្ទមកការិយាល័យទាក់ទងទីផ្សារ (Marketing Communications) តាមលេខ (206) 987-5205 ។*

*ព័ត៌មានដែលចែកជូននេះ ត្រូវបានពិនិត្យមើលដោយបុគ្គលិកគិលានកិច្ចនៅតាមមន្ទីរពេទ្យកុមារ ។ ក៏ប៉ុន្តែ សេចក្តីត្រូវការរបស់កូនអ្នកគឺពិសេសពិសាលណាស់ ។ មុននឹងអ្នកធ្វើសកម្មភាព ឬអាស្រ័យទៅលើព័ត៌មាននេះ សូមពិភាក្សាជាមួយអ្នកផ្តល់ការបំរើផ្នែកថែទាំសុខភាពរបស់កូនអ្នក ។*

Children's Hospital & Regional Medical Center | HARBORVIEW Injury Prevention & Research Center | Washington State 1800 BUCK-L-UP Safety Restraint Coalition | Washington Traffic Safety Commission

© 2004, 2007 Children's Hospital and Regional Medical Center, Seattle, Washington. All rights reserved.

Rev. 6/07
(NPG)
CE484
[KHMER]